**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៚

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

**សកាព្រហ្មទណ្ឌ**

សំណុំរឿងលេខ១៣១

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១

**សាលដីកា**

លេខ៖១២៨ ព្រទ.ក្រIII (រ.ប)

ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១

**គោរពនាមប្រជារាស្ត្រខ្មែរ**

**សាលាឧទ្ធរណ៍ត្បូងឃ្មុំ**

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ និងព្រះរាជក្រឹត្យលេខ នស/រតក/០២២០/១៩៨ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យដំណើរការសាលាឧទ្ធរណ៍តំបន់ បានបើកសវនាការជាសាធារណៈ នៅសាលសាលាឧទ្ធរណ៍ត្បូងឃ្មុំ នាព្រឹក ថ្ងៃចន្ទ ៥កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ ដែលមានសមាសភាពដូចខាងក្រោម៖

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីពិភាក្សាជេញដោលលើ សំណុំរឿងសកាព្រហ្មទណ្ឌលេខ១៣១ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ របស់សាលាឧទ្ធរណ៍ត្បូងឃ្មុំ ដែលមាន៖

១. ឈ្មោ[redacted] ភេទប្រុស អាយុ៣៥ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ឪពុកឈ្មោះគិង ដាំ

(វ) ម្ដាយឈ្មោះ[redacted] (រ) ប្រពន្ធឈ្មោះ ហួញ កន្និញ មានកូន៣នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ) (ម្ចាស់បណ្ដឹងឧទ្ធរណ៍)

២. ឈ្មោះ[redacted] ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ[redacted] (រ) ប្ដីឈ្មោះ[redacted] មានកូន៤នាក់ ទោសពីមុន គ្មាន។ (ក្រៅឃុំ)(ម្ចាស់បណ្ដឹងឧទ្ធរណ៍)

៣. ឈ្មោះ[redacted] ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្ននៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។ ឪពុកឈ្មោះ[redacted] (រ) ម្ដាយឈ្មោះ[redacted] (រ) នៅលីវ ទោសពីមុន គ្មាន។ (ក្រៅឃុំ)(ម្ចាស់បណ្ដឹងឧទ្ធរណ៍)

- **ជាប់ចោទពីបទ÷** ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅចំនុចទំនប់វារីអគ្គិសនី សេសានក្រោម២ ភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ តាមមាត្រា៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

**<u>អំពីអង្គហេតុ</u>**

កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ នៅចំណុចទំនប់វារីអគ្គិសនីសេសានក្រោមពីរ ស្ថិតនៅភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង ឈ្មោះ[redacted] ឈ្មោះ[redacted] និងឈ្មោះ[redacted] បានធ្វើសកម្មភាពញុះញង់ និងរារាំងមិនឲ្យអាជ្ញាធរមូលដ្ឋានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋដែលមាននិន្នាការផ្សេងពីពួកគេ ចូលទៅក្នុងភូមិក្បាលរមាសចាស់ ដើម្បីបំពេញភារកិច្ចទេ។

**បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៣៧៤ព.ស ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តស្ទឹងត្រែង។

**បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខ០៧៣"គ" ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់សាលាដំបូងខេត្តស្ទឹងត្រែងដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១. ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ[redacted] ភេទប្រុសអាយុ៣៥ឆ្នាំ ឈ្មោះ[redacted] ភេទស្រី អាយុ៤៥ឆ្នាំ ឈ្មោះ[redacted] ភេទស្រី អាយុ២៩ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេលចំនួន១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន២.០០០.០០០(ពីរលាន)រៀល គិតចាប់ពីថ្ងៃសាលក្រមចូលស្ថាពរ។

ពីបទ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតនៅក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

២.សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] ឈ្មោះ[redacted]និងឈ្មោះ[redacted]

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**បានឃើញ** ពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះដាំ សំណាង ឈ្មោះដាំ បាង និងឈ្មោះជឿន ស្រីមុំ ប្តឹងឧទ្ធរណ៍គ្រង់ចំនុចទាំងមូល នៃសេចក្តីសម្រេច។

**បានឃើញ** របាយការណ៍រឿង ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ត្បូងឃ្មុំ។

**បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ត្បូងឃ្មុំ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានរបាយការណ៍រឿង

- ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted] កាលពីដំបូង ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ មានកម្មវិធីសែនព្រេនតាមប្រពៃណីជនជាតិភាគតិចដើម្បីសុំសេចក្តីសុខ នៅក្នុងការសែនភូមិតាប្រពៃណីជនជាតិភាគតិចនេះ បានធ្វើឡើងនៅផ្ទះមេកន្ទ្រាញឈ្មោះលោកតា[redacted] មានចាស់ទុំផ្សេងៗទៀត និងមានប្រជាជនចូលរួមព្រមទាំងខ្លួនបានចូលរួមក្នុងការសែនព្រេននោះផងដែរ ខ្លួនមិនបានរារាំងដល់សមត្ថកិច្ចនោះទេ។ ខ្លួនមិនព្រមផ្លាស់ចេញពីទីលំនៅចាស់ ដើម្បីទៅរស់នៅកន្លែងថ្មីដែលគេបានដោះដូរឡើយ បើទោះជាមានទឹកឡើងមកលិចកន្លែងដែលខ្លួនរស់នៅក៏មិនព្រមចាកចេញដែរ។
- ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted] កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៧ មានកម្មវិធីសែនព្រេននៅក្នុងភូមិក្បាលរមាសដែលមានការរៀបចំដោយចាស់ទុំនៅក្នុងភូមិ ពាក់ព័ន្ធនៅក្នុងការរៀបចំពីធីសែនព្រេននេះពួកគាត់មានខ្វះបារី បានឲ្យខ្លួនជាអ្នកទៅទិញបារីខ្លួនក៏បានខ្ចីម៉ូតូបងស្រីរបស់ខ្លួនដើម្បីធ្វើដំណើរទៅទិញបារី នៅផ្លូវច្រកចូលភូមិក្បាលរមាស ខ្លួនបានទិញបារីចំនួន១សុងដាក់នៅកែបម៉ូតូ ក៏បានត្រលប់មកវិញត្រូវបានគេចាប់យកម៉ូតូរបស់ខ្លួនដែលខ្លួនបានខ្ចីបងស្រីរបស់ខ្លួនទៅទិញបារី ខ្លួនបានសុំម៉ូតូវិញប៉ុន្តែគេមិនឲ្យ បន្ទាប់មកខ្លួនក៏បានដើរត្រលប់មកភូមិវិញខ្លួនក៏បានប្រាប់អ្នកភូមិថាគេបានចាប់យកម៉ូតូខ្លួនបាត់ហើយបន្ទាប់មកអ្នកភូមិបានទៅជួយរកម៉ូតូ ចំណែកខ្លួនក៏បាននៅមើលចាស់ទុំរៀបចំពិធីសែនព្រេននៅក្នុងភូមិ។ ខ្លួនមានដីស្រែចំការ ប៉ុន្តែជាដីរបស់ឪពុកម្តាយរបស់ខ្លួនទេ មានចំនួនបួន ទៅប្រាំកន្លែង ហើយដីនេះពុំមានប័ណ្ណកម្មសិទ្ធទេ។ ចំពោះការដែលឲ្យពួកខ្លួនចាកចេញពីទីកន្លែងចាស់ដែលខ្លួនបានរស់នៅ គឺពួកខ្លួនមានការសោកស្តាយចំពោះការចាកចេញការបាត់បង់ផ្ទះសំបែង ដីស្រែចំការ ហើយពួកខ្លួនក៏មានដីមួយចំណែកទៀតដែលអាចបង្ករបង្កើនផលបាន ទើបមិនអាចចាកចេញពីទីកន្លែងនេះបានឡើយ ។
- ស្តាប់អំណានចម្លើយជនជាប់ចោទឈ្មោះ[redacted] ក្នុងពេលនោះខ្លួនបាននៅផ្ទះរៀបចំបាយឲ្យប្អូនៗហូប បន្ទាប់មកក្មេងៗនៅក្នុងភូមិបានប្រាប់ខ្លួនថាពូរបស់ខ្លួនត្រូវបានគេយកម៉ូតូទៅបាត់ហើយ ពេលនោះខ្លួនបានចេញពីផ្ទះទៅដល់មានសួរសមត្ថកិច្ច សមត្ថកិច្ចមិនបានដឹងពីការបាត់ម៉ូតូនោះទេ។ ប្រជាជនមិនព្រមចាក

ចេញមានចំនួនរហូតដល់ទៅ២០០ជាងនាក់ ពួកខ្លួនមិនបានរារាំងចំពោះសមត្ថកិច្ចឡើយ គឺពួកខ្លួនស្មគ្រ័ចិត្តរស់នៅដោយខ្លួនឯងផ្ទាល់។ នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ មានមនុស្សប្រហែលជា១០០នាក់ បានចូលរួមក្នុងពិធីសែនព្រេន។

- ស្តាប់ចម្លើយសាក្សីឈ្មោះ[redacted] ជានាយការិយាល័យព្រហ្មទណ្ឌ៖ ខ្ញុំបាទសូមរក្សាចម្លើយរបស់ខ្ញុំបាទដែលបានឆ្លើយកន្លងមកនៅសាលាដំបូងទុកដដែលទាំងស្រុង។ បន្ថែមពីលើនោះពេលនេះលំនៅដ្ឋានរបស់អ្នកទាំង៣នោះគឺទឹកលិចបាត់ហើយ មិនអាចរស់នៅបានទេ។ ពួកគេបានទៅរស់នៅភូមិថ្មីដាច់ដោយឡែក ហើយក៏ពុំដែលបង្កការរំខានដល់សមត្ថកិច្ច ឬអ្នកផ្សេងទៀតឡើយ។ ដោយឡែករឿងពួកគាត់បានទទួលដីសំណង ឬគាត់មិនទទួលនោះខ្ញុំបាទមិនបានដឹងទេ។ ជាការពិតថានៅពេលដែលកើតមានការតវ៉ានោះមានប្រជាជនច្រើនដែរ ប៉ុន្តែក្រុមគ្រួសារពួកគាត់ដែលមានពួកគាត់៣នាក់ គឺជាមេកើយ ដែលបំផុសបំផុលបងប្អូនគាត់ឲ្យមានការរារាំងសមត្ថកិច្ច ធ្វើឲ្យសមត្ថកិច្ចពិបាកធ្វើការ។

- តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានស្តាប់ការសួរដេញដោល ឃើញថាតំណាងអយ្យការបានធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទឈ្មោះ[redacted] ដោយមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ហើយចៅក្រមជំនុំជម្រះក៏បានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំង៣ សមរម្យហើយផងដែរ ហេតុដូច្នេះតំណាងមហាអយ្យការស្នើសុំឲ្យក្រុមប្រឹក្សាសម្រេចពិចារណាអំពីទោសតាមនីតិវិធី។

- ក្រោយពីបានស្តាប់អំណានរបាយការណ៍រឿង
- ក្រោយពីបានស្តាប់ការកត់សម្គាល់របស់តំណាងមហាអយ្យការ
- ក្រោយពីបានពិនិត្យភស្តុតាងដែលពាក់ព័ន្ធនឹងរឿងក្តី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍**

**យល់ឃើញថា**

១. បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោះ[redacted] និងឈ្មោះ[redacted] ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមព្រហ្មទណ្ឌលេខ០៧៣(គ) ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្ទឹងត្រែង បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ដែលសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា៣៧៥ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយរបស់ជនជាប់ចោទ ឃើញថាបើទោះជាជនជាប់ចោទមិនបានសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់យ៉ាងណាក្តី ប៉ុន្តែសកម្មភាពទាំងអស់នោះគឺមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ទាំងអស់។

សាលាដំបូងបានលើកយកសំអាងហេតុក្នុងការដាក់បន្ទុកជនជាប់ចោទទាំង៣រូប ត្រឹមត្រូវហើយ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុបន្ថែមទៀតដើម្បីដាក់បន្ទុកលើជនជាប់ចោទទេ។

៣. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ ដែលស្នើសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់នោះ ក្រុមប្រឹក្សាជំនុំជម្រះបានពិចារណា និងយល់ស្របចំពោះសេចក្តីសន្និដ្ឋាននេះ។

៤. សាលក្រមលេខ៧៣(គ) ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្ទឹងត្រែង បានសម្រេចត្រឹមត្រូវតាមច្បាប់ហើយ លើកលែងតែចំនុចផ្តន្ទាទោសលើជនជាប់ចោទទាំង៣រូប ដែលសាលាឧទ្ធរណ៍ ពិនិត្យ និងសម្រេចឡើងវិញ ដោយផ្តល់នូវការព្យួរទោសទាំងស្រុង ស្របតាមបញ្ញត្តិមាត្រា១០៦ មាត្រា១០៧ និងមាត្រា១០៨ នៃក្រហ្មទណ្ឌ ដោយពិចារណាទៅលើចរិកលក្ខណៈនៃបទល្មើស ហើយបច្ចុប្បន្ននេះ ឃើញថាជនជាប់ចោទបានរស់នៅដោយសុខដុម ពុំបានបង្កការរំខានណាមួយដល់សមត្ថកិច្ច ក៏ដូចជាបុគ្គលដទៃ ដូច្នេះការផ្តន្ទាទោសដាក់ពន្ធនាគារចំពោះជនទាំង៣ ពុំមានភាពចាំបាច់ទៀតឡើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២០ របស់ជនជាប់ចោទឈ្មោ[redacted] បាង និងឈ្មោះ[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៧៣(គ) ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់សាលាដំបូងខេត្តស្ទឹងត្រែង ទុកជាបានការ លើកលែងតែចំនុចទី១ ដែលផ្តន្ទាទោសឈ្មោ[redacted] ត្រូវកែប្រែ និងសម្រេចជាថ្មី ដូចខាងក្រោម៖

- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោ[redacted]ភេទប្រុសអាយុ៣៥ឆ្នាំ ឈ្មោ[redacted] ភេទប្រុស អាយុ៤៥ឆ្នាំ ឈ្មោះ[redacted]ទស្រី អាយុ២៩ឆ្នាំ (សាវតាជាតិខាងលើ) ដាក់ពន្ធនាគារម្នាក់ៗកំណត់រយៈពេលចំនួន១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន២.០០០.០០០(ពីរលាន)រៀល តែទោសពន្ធនាគារ និងទោសពិន័យនេះត្រូវព្យួរទាំងស្រុង។

ពីបទ ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងប្រឆាំងអ្នករាជការសាធារណៈ ប្រព្រឹត្តនៅចំណុចទំនប់វារីអគ្គិសនីសេសានក្រោម២ ស្ថិតនៅក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៤៩៥ និងមាត្រា៥០៣ នៃក្រមព្រហ្មទណ្ឌ។

៣. សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃពុធ ១៤កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទដាំ សំណាង ជនជាប់ចោទដាំ បាង និងជនជាប់ចោទជឿន ស្រីមុំ។

ទុកសិទ្ធិប្តឹងទាស់និងប្តឹងសាទុក្ខ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**



[redacted] | [redacted] | [redacted] | [redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃ...សុក្រ ១៤កើត...ខែ...បុស្ស...ឆ្នាំ...ឆ្លូវ...ត្រីស័ក ព.ស២៥៦៥

ក្រូចឆ្មារ, ថ្ងៃទី...១៧...ខែ...ធ្នូ...ឆ្នាំ២០២១...

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាឃុំ[illegible]

[redacted]